យាន់តា (ខេមបូឌា)
Yuanta Securities (Cambodia)

លេខបរិវិសកម្ម:
Subscription No.: ____________

កាលបរិច្ឆេទ:
Date: dd / mm / yyyy

# ពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្របំណុល

# DEBT SECURITIES SUBSCRIPTION FORM

## ព័ត៌មានអំពីមូលបត្របំណុល / DEBT SECURITIES INFORMATION

| | | | |
|---|---|---|---|
| ក្រុមហ៊ុនបោះផ្សាយ:<br>Issuer: | អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី<br>**LOLC (Cambodia) Plc.** | ក្រុមហ៊ុនធានាទិញមូលបត្រ:<br>Underwriter: | ក្រុមហ៊ុនមូលបត្រ យាន់តា (ខេមបូឌា) ម.ក<br>**Yuanta Securities (Cambodia) Plc.** |

មូលបត្របំណុលសរុបដែលត្រូវធ្វើសំណើលក់ជាសាធារណៈមានចំនួន **២.០០០.០០០ ឯកតាមូលបត្របំណុល** ដែលតម្លៃចារឹកក្នុងមួយឯកតាមូលបត្របំណុលស្មើនឹង **១០០.០០០ រៀល** ថ្លៃលក់ក្នុងមួយឯកតាមូលបត្របំណុលស្មើនឹង **១០០.០០០ រៀល** ឬ **២៥ ដុល្លារអាមេរិក** និងមានឥណប្រតិទាន **៥ឆ្នាំ**។

The total number of debt securities offered to public are **2,000,000 units** of debt securities which par value per unit of debt securities is **KHR 100,000,** the offering price per unit of debt securities is **KHR 100,000** or **USD 25**, and the maturity is **5 years**.

| ប្រភេទមូលបត្របំណុល<br>Types of Debt Securities | អត្រាគូប៉ុងប្រចាំឆ្នាំ<br>Coupon Rate | រូបិយប័ណ្ណទូទាត់<br>Settlement Currency | ចំនួនទឹកប្រាក់បរិវិសកម្មអប្បបរមា<br>Minimum Subscription Amount |
|---|---|---|---|
| សញ្ញាបណ្ណសាជីវកម្មចីរភាព អិលអូអិលស៊ី មានបុគ្គលធានាទី១<br>LOLC Guaranteed Sustainability Corporate Bonds 1 | 5.75% | USD | USD 500,000 |
| សញ្ញាបណ្ណសាជីវកម្មចីរភាព អិលអូអិលស៊ី មានបុគ្គលធានាទី២<br>LOLC Guaranteed Sustainability Corporate Bonds 2 | 5.75% | KHR | KHR 2,000,000,000 |
| សញ្ញាបណ្ណសាជីវកម្មចីរភាព អិលអូអិលស៊ី ទី១<br>LOLC Sustainability Corporate Bonds 1 | 7.00% | USD | USD 10,000 |
| សញ្ញាបណ្ណសាជីវកម្មចីរភាព អិលអូអិលស៊ី ទី២<br>LOLC Sustainability Corporate Bonds 2 | 7.00% | KHR | KHR 40,000,000 |

សម្រាប់សញ្ញាបណ្ណសាជីវកម្មចីរភាព អិលអូអិលស៊ី មានបុគ្គលធានាទី១ និង សញ្ញាបណ្ណសាជីវកម្មចីរភាព អិលអូអិលស៊ី មានបុគ្គលធានាទី២ ករណីការធ្វើបរិវិសកម្មមានចំនួនច្រើនជាងចំនួនអប្បបរមា ចំនួនទឹកប្រាក់បរិវិសកម្មបន្ថែមជាបន្តបន្ទាប់ត្រូវធ្វើឡើងជាពហុគុណនៃ ១០០.០០០ ដុល្លារអាមេរិក ឬ ៤០០.០០០.០០០ រៀល។

សម្រាប់សញ្ញាបណ្ណសាជីវកម្មចីរភាព អិលអូអិលស៊ី ទី១ និង សញ្ញាបណ្ណសាជីវកម្មចីរភាព អិលអូអិលស៊ី ទី២ ករណីការធ្វើបរិវិសកម្មមានចំនួនច្រើនជាងចំនួនអប្បបរមា ចំនួនទឹកប្រាក់បរិវិសកម្មបន្ថែមជាបន្តបន្ទាប់ត្រូវធ្វើឡើងជាពហុគុណនៃ ១០.០០០ ដុល្លារអាមេរិក ឬ ៤០.០០០.០០០ រៀល។

**For LOLC Guaranteed Sustainability Corporate Bonds 1 and LOLC Guaranteed Sustainability Corporate Bonds 2, if the subscription exceeds the minimum stated above, the subsequent incremental subscription amount shall be made in the multiple of USD 100,000 or KHR 400,000,000.**

**For LOLC Sustainability Corporate Bonds 1 and LOLC Sustainability Corporate Bonds 2, if the subscription exceeds the minimum stated above, the subsequent incremental subscription amount shall be made in the multiple of USD 10,000 or KHR 40,000,000.**

គូប៉ុង និងប្រាក់ដើមនៃមូលបត្របំណុលនីមួយៗ នឹងត្រូវទូទាត់ជារូបិយប័ណ្ណដូចគ្នានឹងរូបិយប័ណ្ណទូទាត់ក្នុងពេលធ្វើបរិវិសកម្ម។

The coupon and principal of each debt securities will be paid in the same currency as settlement currency during subscription.

## ព័ត៌មានរបស់អ្នកធ្វើបរិវិសកម្ម / SUBSCRIBER INFORMATION

**ក. វិនិយោគិនជារូបវន្តបុគ្គល:**

**A. For individual**

គោត្តនាម (អក្សរខ្មែរ) / First Name (Khmer) ____________ នាម (អក្សរខ្មែរ) / Last Name (Khmer) ____________ គោត្តនាម (អក្សរឡាតាំង) / First Name (Latin) ____________ នាម (អក្សរឡាតាំង) / Last Name (Latin) ____________

ថ្ងៃខែឆ្នាំកំណើត / Date of Birth ____________ លេខអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (សម្រាប់ជនបរទេស) / Identification Card or Passport Number (for Foreigner) ____________ មានសុពលភាពរហូតដល់ថ្ងៃខែឆ្នាំ / Valid until ____________

លេខគណនីជួញដូរ / Trading Account Number ____________ ឈ្មោះក្រុមហ៊ុនមូលបត្រ / Securities Firm Name ____________

អាសយដ្ឋានស្នាក់នៅបច្ចុប្បន្ន / Current Residence Address ____________

លេខកូដប្រទេស និងទូរស័ព្ទដៃ / Country Code & Mobile Phone [ ] [ ] អ៊ីមែល / Email ____________

**ខ. វិនិយោគិនជានីតិបុគ្គល:**

**B. For Legal Entity**

១. ឈ្មោះក្រុមហ៊ុន (អក្សរខ្មែរ) / Company Name (Khmer) ____________ ឈ្មោះក្រុមហ៊ុន (អក្សរឡាតាំង) / Company Name (Latin) ____________

លេខចុះបញ្ជីពាណិជ្ជកម្ម / Business Registration ____________ លេខគណនីជួញដូរ / Trading Account Number ____________ ឈ្មោះក្រុមហ៊ុនមូលបត្រ / Securities Firm Name ____________

អាសយដ្ឋានបច្ចុប្បន្នរបស់ក្រុមហ៊ុន / Current Company Address ____________

លេខកូដប្រទេស និងទូរស័ព្ទដៃ / Country Code & Mobile Phone [ ] [ ] អ៊ីមែល / Email ____________

២. គោត្តនាមអ្នកតំណាង (អក្សរខ្មែរ/ឡាតាំង) / First Name of Representative (Khmer/Latin) ____________ នាមអ្នកតំណាង (អក្សរខ្មែរ/ឡាតាំង) / Last Name of Representative (Khmer/Latin) ____________

មុខតំណែង / Position ____________ លេខអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (សម្រាប់ជនបរទេស) / Identification Card or Passport Number (for Foreigner) ____________ មានសុពលភាពរហូតដល់ថ្ងៃខែឆ្នាំ / Valid until ____________

អាសយដ្ឋានស្នាក់នៅបច្ចុប្បន្ន / Current Residence Address ____________

លេខកូដប្រទេស និងទូរស័ព្ទដៃ / Country Code & Mobile Phone [ ] [ ] អ៊ីមែល / Email ____________

## សំណើសុំធ្វើបរិវិសកម្ម / SUBSCRIPTION APPLICATION

| ប្រភេទមូលបត្របំណុល<br>Type of Debt Securities | អត្រាគូប៉ុងប្រចាំឆ្នាំ<br>Coupon Rate | រូបិយប័ណ្ណទូទាត់<br>Settlement Currency | ថ្លៃលក់ក្នុងមួយឯកតា [ក]<br>Price per Unit [A] | ចំនួនមូលបត្របំណុល [ខ]<br>Number of Debt Securities [B] | ចំនួនទឹកប្រាក់សរុប [គ]<br>Total Amount [C]<br>[ C = A x B ] |
|---|---|---|---|---|---|
| សញ្ញាបណ្ណសាជីវកម្មចីរភាព អិលអូអិលស៊ី មានបុគ្គលធានាទី១<br>LOLC Guaranteed Sustainability Corporate Bonds 1 | 5.75% | USD | USD 25 | | USD |
| សញ្ញាបណ្ណសាជីវកម្មចីរភាព អិលអូអិលស៊ី មានបុគ្គលធានាទី២<br>LOLC Guaranteed Sustainability Corporate Bonds 2 | 5.75% | KHR | KHR 100,000 | | KHR |
| សញ្ញាបណ្ណសាជីវកម្មចីរភាព អិលអូអិលស៊ី ទី១<br>LOLC Sustainability Corporate Bonds 1 | 7.00% | USD | USD 25 | | USD |
| សញ្ញាបណ្ណសាជីវកម្មចីរភាព អិលអូអិលស៊ី ទី២<br>LOLC Sustainability Corporate Bonds 2 | 7.00% | KHR | KHR 100,000 | | KHR |
| | | | | ចំនួនទឹកប្រាក់សរុបរួម៖<br>Grand Total: | USD |
| | | | | | KHR |
| | | | | ចំនួនទឹកប្រាក់តម្កល់ជាក់ស្តែង៖<br>Actual Deposit: | USD |
| | | | | | KHR |

ខ្ញុំបានតម្កល់ប្រាក់ ១០០ (មួយរយ) ភាគរយ សម្រាប់ទូទាត់មូលបត្របំណុលដែលខ្ញុំបានធ្វើបរិវិសកម្មខាងលើតាមមធ្យោបាយទូទាត់៖
I deposited 100% of the total amount due from subscription of debt securities through:

☐ ប្រាក់សុទ្ធ Cash ☐ គណនីជួញដូរ Trading Account ☐ មូលប្បទានបត្រ Cheque ☐ ផ្ទេរតាមធនាគារ Bank Transfer

សូមផ្ទេរមូលបត្របំណុលដែលបានបែងចែកមកឱ្យខ្ញុំ ចូលក្នុងគណនីជួញដូរមូលបត្ររបស់ខ្ញុំខាងលើ ស្របតាមបញ្ជីឈ្មោះអ្នកធ្វើបរិវិសកម្មបានជោគជ័យ ដែលគ្រប់គ្រង និងបញ្ជូនទៅប្រតិបត្តិកររក្សាទុកមូលបត្រដោយភ្នាក់ងារបញ្ជិកាមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយគឺ ធនាគារ អេស៊ីលីដា ភីអិលស៊ី។
Please transfer the allotted debt securities to my trading account mentioned above according to the List of Successful Subscribers managed and submitted to Securities Depository Operator by the Issuer's Registrar, ACLEDA Bank Plc.

## ព័ត៌មានពាក់ព័ន្ធនឹងការផ្ទេរប្រាក់កក់ / REFUND INFORMATION

ករណីខ្ញុំមិនទទួលបានមូលបត្របំណុលទៅតាមការស្នើសុំធ្វើបរិវិសកម្ម ខ្ញុំមានបំណងទទួលប្រាក់កក់បរិវិសកម្មដែលនៅសល់ (ដកចេញនូវរាល់ការចំណាយ ប្រសិនបើមាន) តាមរយៈមធ្យោបាយណាមួយខាងក្រោម៖
In case I do not receive the number of debt securities as I subscribed, I would like to receive the remaining Subscription Deposit (subtract all the expenses, if any) through the any of below methods:

☐ ផ្ទេរទៅគណនីជួញដូរ / Refund to Trading Account

☐ ផ្ទេរទៅគណនីធនាគារ៖ Refund to Bank Account

ឈ្មោះគណនី Account Name ______________________ លេខគណនី Account No. ______________________

ឈ្មោះធនាគារ Bank Name ______________________ លេខកូដ SWIFT Swift Code ______________________

* សម្គាល់៖ ម្ចាស់គណនី និង វិនិយោគិនដែលមិនទទួលបានជោគជ័យ ត្រូវតែជាបុគ្គលតែមួយ។ គណនីរួម មិនត្រូវបានអនុញ្ញាត។
* Note: The bank account owner and Unsuccessful Investor must be the same person. Joint Accounts are not allowed.

## ឯកសារភ្ជាប់ / ATTACHED DOCUMENT

☐ វិក្កយបត្រតម្កល់ប្រាក់ Proof of Deposit

## សេចក្តីថ្លែងរបស់អ្នកធ្វើបរិវិសកម្ម / SUBSCRIBER STATEMENT

នៅក្នុងការធ្វើបរិវិសកម្មមូលបត្របំណុលនេះ ខ្ញុំបានទទួលឯកសារផ្តល់ព័ត៌មានក្នុងទម្រង់ជា៖
In subscribing to the debt securities, I received the disclosure document in the form of:

☐ ច្បាប់ចម្លង Hard copy ☐ ឧបករណ៍ផ្ទុក Storage device ☐ អ៊ីមែលផ្ទុក Email storage ☐ តាមរយៈគេហទំព័រ Website ______________________ ឬ or ☐ ផ្សេងពីនេះ Other ______________________

ការធ្វើបរិវិសកម្ម និងការទូទាត់ ត្រូវធ្វើឡើងដោយអ្នកធ្វើបរិវិសកម្មស្របតាមលក្ខខណ្ឌដែលមានចែងក្នុងឯកសារផ្តល់ព័ត៌មាន។ ខ្ញុំយល់ព្រមឱ្យក្រុមហ៊ុនបោះផ្សាយមានសិទ្ធិបដិសេធ ក្នុងករណីការស្នើសុំធ្វើបរិវិសកម្មរបស់ខ្ញុំមិនគោរពតាមលក្ខខណ្ឌបរិវិសកម្ម។ ខ្ញុំយល់ព្រមទិញមូលបត្របំណុលក្នុងចំនួនកំណត់ដូចខាងលើ ឬចំនួនមូលបត្របំណុលដែលក្រុមហ៊ុនបានបែងចែកមកឱ្យខ្ញុំ។ ខ្ញុំយល់ព្រមមិនលុបចោលការធ្វើបរិវិសកម្មរបស់ខ្ញុំទេ និងយល់ព្រមទទួលប្រាក់សងត្រឡប់មកវិញ ក្នុងករណីការធ្វើបរិវិសកម្មត្រូវបានបដិសេធ ឬការធ្វើបរិវិសកម្មរបស់ខ្ញុំមិនសម្រេចបានតាមការស្នើសុំទាំងអស់របស់ខ្ញុំ។ ខ្ញុំបានអានឯកសារផ្តល់ព័ត៌មានដោយម៉ត់ចត់មុនពេលធ្វើបរិវិសកម្ម និងយល់ព្រមដោយស្ម័គ្រចិត្តតាមលក្ខខណ្ឌនៃសំណើបោះផ្សាយលក់មូលបត្របំណុលដូចមានចែងនៅក្នុងឯកសារផ្តល់ព័ត៌មាន និងទទួលស្គាល់ថា ការវិនិយោគលើមូលបត្របំណុលមានហានិភ័យពាក់ព័ន្ធ។
The subscription and payment made by subscriber shall be in accordance with the conditions specified in the disclosure document. I agree and acknowledge that issuer shall be entitled to deny if my subscription does not comply with the subscription terms and conditions. I undertake to purchase the number of debt securities as stated above or the number of debt securities allotted to me. I shall not cancel my subscription and accept refund if the subscription is denied or not fully allotted. I read thoroughly the disclosure document before subscribing and voluntarily agree with the terms and conditions of the offering of debt securities as specified in the Disclosure Document and acknowledge that the investment in debt securities is risk associated.

វិនិយោគិន និងក្រុមហ៊ុនធានាទិញមូលបត្រ បានអាន យល់ច្បាស់ និងយល់ព្រមលើលក្ខខណ្ឌដែលបានចែងក្នុងសេវាបរិវិសកម្មដូចដែលមានភ្ជាប់មកជាមួយ។
The Investor and the Underwriter named herein have read, understood and agreed on the terms and conditions of the Subscription Service as attached hereto.

| ហត្ថលេខា-ត្រា និងឈ្មោះអ្នកធ្វើបរិវិសកម្ម<br>Signature-Seal and Name of Subscriber | ហត្ថលេខា និងឈ្មោះភ្នាក់ងារក្រុមហ៊ុនមូលបត្រ/ភ្នាក់ងារចែកចាយលក់<br>Signature and Name of Securities Representative/Selling Agent | ហត្ថលេខា ត្រា និងឈ្មោះប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រ ឬអគ្គនាយកប្រតិបត្តិ<br>Signature-Seal and Name of Head of Securities Representatives or CEO |
|---|---|---|
| ______________________ | ______________________ | ______________________ |

* ក្រុមហ៊ុនធានាទិញមូលបត្រ ឬតំណាងភ្នាក់ងារលក់ត្រូវពន្យល់វិនិយោគិនអំពីខ្លឹមសារនៃសេវាបរិវិសកម្មដែលមានចែងដូចខាងក្រោមនេះ។
* The Underwriter or its authorized selling agents shall explain to the Investor the terms of the Subscription Service prescribed hereunder.
** វិនិយោគិនទទួលខុសត្រូវលើលទ្ធផល និងរាល់ហេតុការណ៍ទាំងឡាយដែលកើតឡើង ឬដែលអាចនឹងកើតឡើងពាក់ព័ន្ធនឹងការធ្វើបរិវិសកម្ម។ ក្រុមហ៊ុនធានាទិញមូលបត្រ និងតំណាងភ្នាក់ងារលក់មិនទទួលខុសត្រូវលើលទ្ធផល និងរាល់ហេតុការណ៍ទាំងនោះទេ។
** The Investor hereby assumes full responsibility for the outcome and all matters that arise or eventuate in connection with the Subscription. The Underwriter and its authorized selling agents do not and shall not take any responsibility with respect to such outcome or matters.

# សេវាបរិវិសកម្ម

## SUBSCRIPTION SERVICE

វិនិយោគិន និងក្រុមហ៊ុនធានាទិញមូលបត្របានអាន និងយល់ព្រមលើលក្ខខណ្ឌនៃសេវាបរិវិសកម្មដូចខាងក្រោម៖
The Investor and the Underwriter have hereby reviewed and agreed on the following terms and conditions of this Subscription Service.

### ១. លក្ខខណ្ឌទូទៅ / 1. GENERAL CONDITIONS

១.១ ការដាក់ពាក្យស្នើសុំត្រូវធ្វើលើពាក្យស្នើសុំដែលបានរៀបចំដោយក្រុមហ៊ុនមូលបត្រ យាន់តា (ខេមបូឌា) ម.ក («**ក្រុមហ៊ុនមូលបត្រ យាន់តា**»)។
1.1 Application must be made on the application form that has been prepared by Yuanta Securities (Cambodia) Plc. ("**YSC**").

១.២ ពាក្យស្នើសុំត្រូវធ្វើឡើងដោយនីតិបុគ្គលដែលបានចុះបញ្ជី ឬរូបវន្តបុគ្គលដែលមានសមត្ថភាពតាមផ្លូវច្បាប់។ អនីតិជន ឬបុគ្គលដែលមានសតិមិនគ្រប់គ្រាន់មិនត្រូវបានចាត់ទុកថាមានសមត្ថភាពតាមផ្លូវច្បាប់ក្នុងគោលបំណងនៃការដាក់ពាក្យស្នើសុំនេះទេ។
1.2 Application must be made by a registered legal entity or an existing individual with legal capacity. For avoidance of any doubt, a minor or a person with unsound mind shall not be considered as having legal capacity for the purpose of this Application.

១.៣ ពាក្យស្នើសុំត្រូវបំពេញឲ្យបានពេញលេញ និងគោរពតាមលក្ខខណ្ឌតម្រូវដែលមាន។
1.3 Application must be complete and satisfy the requirements contained herein.

១.៤ បុគ្គលដាក់ពាក្យស្នើសុំត្រូវផ្តល់នូវ (១) ព័ត៌មានលម្អិតអំពីគណនីជួញដូរមូលបត្រដែលមាននៅក្រុមហ៊ុនមូលបត្រណាមួយដែលទទួលអាជ្ញាបណ្ណពី ន.ម.ក. (២) ព័ត៌មានលម្អិតអំពីគណនីធនាគារសម្រាប់ការផ្ទេរប្រាក់ត្រឡប់ទៅវិញ (ប្រសិនបើមាន) និង (៣) ឯកសារផ្សេងទៀតដែលស្នើសុំដោយក្រុមហ៊ុនមូលបត្រ យាន់តា ឬភ្នាក់ងារលក់របស់ក្រុមហ៊ុនមូលបត្រ យាន់តា នៅពេលដាក់ពាក្យស្នើសុំ ។
1.4 An applicant should provide its (1) details of the Trading Account at one of the securities firms licensed by the SERC, (2) details of a bank account for the purpose of receiving the refund (if any), and (3) any other documents requested by YSC or any one of its authorized selling agents at the time of submission of the Application.

១.៥ ពាក្យស្នើសុំដែលមានព័ត៌មានមិនពិត ឬមិនត្រឹមត្រូវនឹងត្រូវបានបដិសេធចោល ហើយបុគ្គលដាក់ពាក្យស្នើសុំអាចនឹងត្រូវពិន័យ ឬផ្តន្ទាទោសតាមច្បាប់ ដែលក្នុងករណីនេះ ក្រុមហ៊ុនមូលបត្រ យាន់តា មិនទទួលខុសត្រូវឡើយ។
1.5 Application containing false statement or incorrect information shall be rejected and the relevant applicant may be subject to penalties or prosecution under the applicable law for which YSC assumes or undertakes no responsibility.

១.៦ បុគ្គលដាក់ពាក្យស្នើសុំមិនអាចដាក់ពាក្យស្នើសុំលើសពីមួយទេ ហើយក្រុមហ៊ុនមូលបត្រ យាន់តា សូមរក្សាសិទ្ធិបដិសេធពាក្យស្នើសុំដែលដាក់ច្រើនដង ឬពាក្យស្នើសុំដែលសង្ស័យថាត្រូវបានដាក់ច្រើនដង។
1.6 An applicant cannot submit more than one application and YSC reserves the right to reject all multiple applications or those that are suspected as multiple applications in the opinion of YSC.

១.៧ នៅពេលដាក់ពាក្យស្នើសុំតាមរយៈអ្នកតំណាង ពាក្យស្នើសុំត្រូវតែភ្ជាប់ជាមួយនូវលិខិតផ្ទេរសិទ្ធិដែលមានសុពលភាព។
1.7 When applying through a representative or a proxy, the Application must be accompanied by a valid power of attorney or letter of proxy.

១.៨ ពាក្យស្នើសុំធ្វើបរិវិសកម្មរបស់វិនិយោគិនដែលបានដាក់មកក្រុមហ៊ុនមូលបត្រ យាន់តា រួចហើយ មិនអាចដក ឬលុបចោលវិញបានទេ។
1.8 Subscription Application Form that has been submitted to YSC cannot be withdrawn or cancelled.

១.៩ លើកលែងមានការបញ្ជាក់ផ្សេងពីនេះ ពាក្យកាត់នៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវមានន័យដូចដែលមានចែងក្នុងឯកសារផ្តល់ព័ត៌មានរបស់ក្រុមហ៊ុនបោះផ្សាយដែលបានចុះបញ្ជីនៅ ន.ម.ក.។
1.9 Unless stated otherwise, all capitalized terms herein shall have the meaning stipulated or referred to in the Issuer's Disclosure Document that has been registered with the SERC.

### ២. ការធ្វើបរិវិសកម្ម / 2. SUBSCRIPTION

២.១ ការដាក់តម្កល់ប្រាក់សម្រាប់ការធ្វើបរិវិសកម្ម («**ប្រាក់តម្កល់បរិវិសកម្ម**») ត្រូវមានចំនួន ១០០% នៃថ្លៃមូលបត្របំណុលសរុបដែលបានធ្វើបរិវិសកម្មក្នុងពាក្យស្នើសុំ។ ទឹកប្រាក់ដែលដាក់តម្កល់នឹងមិនមានការប្រាក់ទេ លើកលែងតែមានការបញ្ជាក់ច្បាស់លាស់ពី ន.ម.ក.។
2.1 Deposit for the subscription (the "**Subscription Deposit**") shall be 100% of the total value of the amount of debt securities that have been subscribed in the Application, and no interest shall accrue on the Subscription Deposit unless expressly instructed otherwise by the SERC.

២.២ ក្នុងករណីមានភាពខុសគ្នារវាងចំនួនមូលបត្របំណុលសរុបដែលបានធ្វើបរិវិសកម្ម និងចំនួនមូលបត្របំណុលដែលអាចធ្វើបរិវិសកម្មបានជាមួយនឹងប្រាក់តម្កល់បរិវិសកម្ម វិនិយោគិនត្រូវសន្មតថាបានធ្វើបរិវិសកម្មលើចំនួនទឹកប្រាក់តម្កល់ធ្វើបរិវិសកម្ម។
2.2 In the event of any discrepancy between the subscribed amount and the amount that can be subscribed with the Subscription Deposit, the Investor shall be deemed to have subscribed for the amount corresponding to the Subscription Deposit.

២.៣ ប្រាក់តម្កល់បរិវិសកម្មត្រូវផ្ទេរឲ្យបានគ្រប់ចំនួនតាមការណែនាំរបស់ក្រុមហ៊ុនមូលបត្រ យាន់តា។ ក្រុមហ៊ុនមូលបត្រ យាន់តា មិនទទួលខុសត្រូវលើការភាន់ច្រឡំ ឬយឺតយ៉ាវណាមួយដែលកើតឡើងក្នុងអំឡុងពេលផ្ទេរប្រាក់ ដែលបណ្តាលមកពីការមិនគោរពតាមការណែនាំខាងលើឡើយ។ ប្រាក់តម្កល់បរិវិសកម្មដែលបានផ្ទេរទៅក្នុងគណនីបរិវិសកម្មរបស់ក្រុមហ៊ុនបោះផ្សាយរួចមិនអាចដកវិញបានទេ លើកលែងតែក្នុងករណីដូចមានចែងក្នុងប្រការ ៤ នៃសេវាបរិវិសកម្មនេះ។

2.3 Subscription Deposit must be transferred or remitted in full, in accordance with YSC’s instructions. YSC assumes no responsibility for any error or delay in the transfer or remittance as a result of a failure to follow the aforementioned instructions. Subscription Deposit that has been transferred to the Issuer’s Subscription Account cannot be withdrawn, except as specified in point 4 of this Subscription Service.

## ៣. ការបែងចែកមូលបត្របំណុល / 3. ALLOTMENT

ការបែងចែកមូលបត្របំណុលជូនវិនិយោគិន គឺស្ថិតនៅក្រោមការសម្រេចចិត្តដោយឆន្ទានុសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនធានាទិញមូលបត្រ។ ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនធានាទិញមូលបត្រ អាចបែងចែកចំនួនណាមួយនៃមូលបត្របំណុលជូនវិនិយោគិនណាមួយ ឬអាចបដិសេធធ្វើការបែងចែកមូលបត្របំណុលដែលបានធ្វើបរិវិសកម្មដោយវិនិយោគិនណាមួយ។

The allocation of the debt securities to investors shall be at the absolute discretion of the issuer and the Underwriter. The issuer and the Underwriter may allocate any amount of the debt securities to any person or may refuse to allocate the debt securities subscribed by any investors as they deem appropriate.

## ៤. ផ្ទេរប្រាក់កក់ / 4. REFUND

៤.១ ទឹកប្រាក់ដែលនៅសល់ពីប្រាក់តម្កល់បរិវិសកម្មបន្ទាប់ពីដំណាក់កាលបរិវិសកម្ម ត្រូវផ្ទេរត្រឡប់ទៅបុគ្គលដាក់ពាក្យស្នើសុំវិញនៅក្នុងរូបិយប័ណ្ណដូចគ្នាទៅនឹងរូបិយប័ណ្ណប្រាក់តម្កល់បរិវិសកម្ម តាមរយៈមធ្យោបាយដែលបានបញ្ជាក់ក្នុងពាក្យស្នើសុំ ឬតាមវិធីដែលសមស្របផ្សេងទៀត។

4.1 Any remainder of the Subscription Deposit after the Subscription Period shall be refunded to the corresponding Applicants in the same currency as subscription deposit through the method stipulated in their Application or via any other reasonable methods.

៤.២ ក្រុមហ៊ុនមូលបត្រ យាន់តា មិនទទួលខុសត្រូវលើការភាន់ច្រឡំណាមួយដែលកើតឡើងក្នុងអំឡុងពេលផ្ទេរប្រាក់ត្រឡប់ទៅវិញ ដែលបណ្តាលមកពីព័ត៌មានគណនីធនាគារនៅក្នុងពាក្យស្នើសុំមិនត្រឹមត្រូវឡើយ។

4.2 YSC assumes no responsibility for any error in the refund due to inaccurate bank account details in the Application.

៤.៣ រាល់ការចំណាយ និងកម្រៃណាមួយដោយផ្នែក ឬទាំងអស់ដែលពាក់ព័ន្ធនឹងការផ្ទេរត្រឡប់ទៅវិញ រួមទាំងការចំណាយ និងកម្រៃសេវាលើការផ្ទេរតាមធនាគារ ត្រូវជាបន្ទុករបស់អ្នកស្នើសុំ។

4.3 Any and all expenses, fees and charges related to the refund including, without limitation, the bank transfer fee and service change, shall be borne by the Applicant.

## ៥. អំណាចនៃត្រារបស់ក្រុមហ៊ុនធានាទិញមូលបត្រ និងទម្រង់ហត្ថលេខារបស់ប្រធានភ្នាក់ងារ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ

## 5. POWER OF SEAL OF THE UNDERWRITER AND SIGNATURE IMAGE OF THE UNDERWRITER’S HEAD OF SECURITIES REPRESENTATIVES AND SECURITIES REPRESENTATIVE

ត្រារបស់ក្រុមហ៊ុនមូលបត្រ យាន់តា និងទម្រង់ហត្ថលេខារបស់ប្រធានភ្នាក់ងារ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រនៃក្រុមហ៊ុនមូលបត្រ យាន់តា ដែលមាននៅលើពាក្យស្នើសុំធ្វើបរិវិសកម្ម និងវិក្កយបត្របរិវិសកម្មមូលបត្រ ត្រូវចាត់ទុកជាត្រាដើមរបស់ក្រុមហ៊ុនមូលបត្រ យាន់តា និងហត្ថលេខាដើមរបស់ប្រធានភ្នាក់ងារ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រនៃក្រុមហ៊ុនមូលបត្រ យាន់តា និងមានអានុភាពតាមផ្លូវច្បាប់ដូចត្រាដើម និងហត្ថលេខាដើមតទៅ។

YSC’s seal hereunder and the signature image of YSC’s Head of Securities Representatives as they appear on the Subscription Form and Receipt for Subscription shall be deemed as the original of the seal of YSC and the original signatures of YSC’s Head of Securities Representatives and be construed as having the same legal effect as to the true originals thereof.

## ៦. ផ្សេងៗ / 6. MISCELLANEOUS

៦.១ លទ្ធផលបរិវិសកម្មនឹងត្រូវប្រកាសជូនវិនិយោគិនតាមរយៈគេហទំព័រផ្លូវការរបស់ក្រុមហ៊ុនបោះផ្សាយ ឬគេហទំព័រផ្លូវការរបស់ក្រុមហ៊ុនមូលបត្រ យាន់តា ឬគេហទំព័រផ្លូវការរបស់ភ្នាក់ងារលក់របស់ក្រុមហ៊ុនមូលបត្រ យាន់តា។

6.1 Subscription result shall be announced to investors via the official website of the Issuer, YSC’s official website or authorized selling agents’ websites.

៦.២ ក្រុមហ៊ុនមូលបត្រ យាន់តា រក្សាសិទ្ធិកែប្រែលក្ខខណ្ឌដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ។

6.2 YSC reserves the right to amend the terms and conditions contained herein.

៦.៣ បុគ្គលដាក់ពាក្យស្នើសុំដែលមានសំណួរពាក់ព័ន្ធនឹងពាក្យស្នើសុំនេះ គួរស្វែងរកការបញ្ជាក់ពីក្រុមហ៊ុនមូលបត្រ យាន់តា។

6.3 An Applicant with queries regarding the Application or any of the matters contained herein should seek clarification from YSC.